ព័ត៌មានសហគមន៍នេសាទនៅតំបន់ឆ្នេរ

# សហគមន៍នេសាទកំពង់សាមគ្គី ខេត្តកំពត (២០១៧)

## ស្ថានភាពទូទៅ

សហគមន៍នេសាទកំពង់សាមគ្គីមានទីតាំងស្ថិតនៅភូមិកំពង់នង់ និងភូមិកំពង់ត្នោត ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត។ សហគមន៍នេសាទនេះមានផ្ទៃដីទំហំ៥៧៧ហិកតា (យោងតាមប្រកាសលេខ១២៣) ក្នុងនោះមានកន្លែងគ្រប់គ្រងស្មៅសមុទ្រទំហំ៥០ហិកតា កន្លែងគ្រប់គ្រងព្រៃកោងកាងទំហំ៧២ហិកតា និងតំបន់វាលខ្សាច់ ឬភក់ទំហំ៤៥,៤៦ហិកតា មានសមាជិកសរុបចំនួន៤០៣នាក់ (ស្រី១៥៥នាក់) និងមានសមាជិកគណៈកម្មការសហគមន៍នេសាទចំនួន១១នាក់ (ស្រី០២នាក់)។



**កាលបរិច្ឆេទបង្កើតសហគមន៍ ៖** ឆ្នាំ២០០២

**ការចុះបញ្ជី ៖** បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

### ការគាំទ្រពីអ្នកពាក់ព័ន្ធ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត
- ខណ្ឌរដ្ឋបាលជលផលខេត្តកំពត
- មន្ទីរបរិស្ថានខេត្តកំពត
- មន្ទីរទេសចរណ៍ខេត្តកំពត
- អាជ្ញាធរមូលដ្ឋាន

### ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល

- សហភាពអឺរ៉ុប
- អង្គការសំលេងសហគមន៍
- អង្គការអាក់សិនអេត
- មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា
- អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
- អង្គការហ្វ៊ីរ៉ុម ស៊ីដ

### ព័ត៌មានទំនាក់ទំនង

**ទូរស័ព្ទ៖** (+៨៥៥) ៨៨ ៨៣៦ ០៦៧៣

**អាសយដ្ឋាន៖** ភូមិកំពង់នង់ និងភូមិកំពង់ត្នោត ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត។

**ឯកសារយោង៖**

- លក្ខន្តិកៈសហគមន៍នេសាទកំពង់សាមគ្គី
- បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទកំពង់សាមគ្គី
- ផែនទីសហគមន៍នេសាទកំពង់សាមគ្គី
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍កំពង់សាមគ្គី
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់សាមគ្គី
- ប្រកាសលេខ១២៣ ស្តីពីការចុះបញ្ជីសហគមន៍នេសាទ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១

## មុខរបរចិញ្ចឹមជីវិត

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ រួមមាន៖ ការធ្វើនេសាទ និងទេសចរណ៍។

មុខរបរចិញ្ចឹមជីវិតមិនមានបញ្ជាក់លំអិតនៅក្នុងឯកសារទេ ប៉ុន្តែមានបង្ហាញថា សមាជិកសហគមន៍នេសាទពឹងអាស្រ័យជាសំខាន់លើវិស័យកសិកម្ម និងការធ្វើស្រែអំបិល។

## ជនជាតិ និងសាសនា

**ជនជាតិ៖** មិនមានព័ត៌មាន
**សាសនា៖** មិនមានព័ត៌មាន

## ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍៖ មិនមានព័ត៌មាន

## អ្នកនេសាទ

ចំនួនអ្នកនេសាទជាសមាជិកក្នុងសហគមន៍សរុប៖ ៣៣០គ្រួសារ

ចំនួនអ្នកនេសាទមិនមែនជាសមាជិកសហគមន៍ដែលរស់នៅក្នុងសហគមន៍សរុប៖ ៣០០គ្រួសារ (ស្រី១០០នាក់)

ចំនួនអ្នកនេសាទដែលមកពីខាងក្រៅសហគមន៍សរុប៖ ១.១៥០នាក់ (ស្រី១៨៥នាក់)



## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវរៀបចំឡើងដោយអនុលោមតាមប្រការលេខ២៣ នៃប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ ការនេសាទ និងកសិកម្ម លក្ខណៈនៃដែននេសាទ សកម្មភាពពាក់ព័ន្ធនឹងការនេសាទ និងបញ្ហាដែលកើតមាននៅក្នុងសហគមន៍។ សហគមន៍នេសាទកំពង់សាមគ្គីបានរៀបចំផែនការបីឆ្នាំ សម្រាប់ឆ្នាំ២០១៨-២០២១។ ផែនការនេះបានបង្ហាញនូវទស្សនៈវិស័យរយៈពេលបីឆ្នាំ ដែលអាចរួមចំណែកក្នុងការធានាបាននូវការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព។

**ផែនការថវិកា៖** ទោះបីជាសហគមន៍នេសាទកំពង់សាមគ្គីធ្វើការប្រមូលវិភាគទានពីសមាជិករបស់ខ្លួនជាប្រចាំឆ្នាំ ប៉ុន្តែវិភាគទាន ដែលប្រមូលបានមិនអាចធានាបាននូវនិរន្តរភាពសាច់ប្រាក់សម្រាប់សហគមន៍នេសាទនោះឡើយ។

## តំបន់ការពារ និងកន្លែងគ្រប់គ្រងជលផល

ផ្ទៃដីទំហំ៧២ហិកតាត្រូវបានចាត់ទុកជាកន្លែងគ្រប់គ្រងព្រៃកោងកាងនិង៥០ហិកតាត្រូវបានចាត់ទុកជាកន្លែងគ្រប់គ្រងស្មៅសមុទ្រ។ ក្រោមការគាំទ្របច្ចេកទេសក្នុងការងារពង្រឹង និងអភិវឌ្ឍសហគមន៍ អង្គការអាក់សិនអេត និងអង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា សហគមន៍បានរៀបចំផ្ទៃដីទំហំ ៤៥,៤៦ហិកតា សម្រាប់គ្រប់គ្រងដីភក់ និងខ្សាច់។

## កន្លែងគ្រប់គ្រងស្មៅសមុទ្រ និងព្រៃកោងកាងរបស់សហគមន៍នេសាទ

កន្លែងសម្រាប់រៀបចំបង្កើតទេសចរណ៍ធម្មជាតិមានផ្ទៃដីទំហំ៧២ហិកតា ក្នុងនោះកន្លែងសម្រាប់ការអភិវឌ្ឍន៍គម្រោងផ្ទះស្នាក់នៅមានផ្ទៃដីទំហំ៤០ហិកតា និងសម្រាប់កន្លែងគ្រប់គ្រងព្រៃកោងកាងដែលជាតំបន់ទាក់ទាញអ្នកទេសចរណ៍មានផ្ទៃដីទំហំ៣២ហិកតា។



## ធនធានជលផល

**មច្ឆជាតិ៖** ត្រី២០ប្រភេទ វារីសត្វ២៧ប្រភេទ ព្រមទាំងប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិផ្សេងទៀត។
**ផលនេសាទ៖** ត្រីក្នុងមួយខែរកបាន១៥ថ្ងៃ ចន្លោះពី ៨៥០គីឡូក្រាម-៩០០គីឡូក្រាម។

## បញ្ហាប្រឈម

ផ្អែកលើផ្នែកសាវតារបស់សហគមន៍នេសាទនេះបានឱ្យដឹងថា សហគមន៍បានប្រឈមនឹងបញ្ហាជាច្រើនរួមមានការរំលោភដីធ្លីពីក្រុមអ្នកមានអំណាច និងក្រុមហ៊ុនមួយចំនួនបានរំលោភយកដីព្រៃកោងកាងមកធ្វើជាកម្មសិទ្ធឯកជន និងការនេសាទត្រីខុសច្បាប់ក្នុងកំឡុងឆ្នាំ២០០៧ ទៅ ២០០៨។ នៅក្នុងផែនការបីឆ្នាំរបស់សហគមន៍បានបញ្ជាក់ថា សហគមន៍មិនអាចតាមដានអំពីគម្រោងអភិវឌ្ឍន៍កំពតថ្មី និងផល្លាគ្រុបបាននោះទេ។ សមាជិកសហគមន៍ក៏មិនបានចូលរួមនៅក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងទាំងនោះដែរ។

ផលិតដោយ

Open Development Cambodia
អង្គការទិន្នន័យអំពីការអភិវឌ្ឍ
C.W.D.C.C
actionaid

ជំនួយរបស់សហភាពអឺរ៉ុប

សហភាពអឺរ៉ុប

ឯកសារនេះរចនាដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) សហការជាមួយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងអង្គការអាកសិនអេតដោយគាំទ្រថវិកាពីសហភាពអឺរ៉ុប។ទិន្នន័យនិងព័ត៌មាននៅលើផ្ទាំងព័ត៌មានទិន្នន័យសហគមន៍នេសាទនៅតំបន់ឆ្នេរដកស្រង់ចេញពីឯកសារយោងដែលមានស្រាប់ និងមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។